**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ.៩៩៣០.សហវ....អគរ

ថ្ងៃ ចន្ទ ១០រោច ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២១

**ជម្រាបជូន**

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

**កម្មវត្ថុ:** ការធ្វើបច្ចុប្បន្នភាពលេខកូដទំនិញ ដែលទទួលបានការលើកទឹកចិត្តពន្ធនិង/ឬអាករជាបន្ទុករបស់រដ្ឋ នាពេលកន្លងមក ឱ្យស្របតាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ានឆ្នាំ២០២២ (AHTN 2022)។

**យោង:**
- លិខិតលេខ ៨៧៥០ សហវ.អគរ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីការធ្វើបច្ចុប្បន្នភាពលេខកូដទំនិញដែលទទួលបានការលើកទឹកចិត្តពន្ធអាករជាបន្ទុករដ្ឋនាពេលកន្លងមកឱ្យស្របជាមួយនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ានឆ្នាំ២០១៧ (AHTN 2017)
- សារាចរណែនាំលេខ ១៧០៤ សជណ.ហជ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីករណីសំណើសុំគោលការណ៍បញ្ចុះអត្រាអាករនាំចេញលើមុខទំនិញប្រភេទឈើដាំនិងវត្ថុធ្វើពីឈើដាំ ដើម្បីលើកទឹកចិត្តវិនិយោគិនដាំឈើនៅក្នុងប្រទេសកម្ពុជា របស់ក្រសួងបរិស្ថាន
- ប្រកាសលេខ ៧៨២ សហវ.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ជ្រាបថា លេខកូដមុខទំនិញដែលទទួលបានការលើកទឹកចិត្តពន្ធនិង/ឬអាករជាបន្ទុករបស់រដ្ឋស្របតាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ានឆ្នាំ២០១៧ (AHTN 2017) ត្រូវបានធ្វើបច្ចុប្បន្នភាព ឱ្យស្របតាមនាមវលីនៃតារាងពន្ធគយស៊ីចង្វាក់របស់អាស៊ានឆ្នាំ២០២២ (AHTN 2022) ដូចមានជាតារាងភ្ជាប់ជាមួយ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** ចាត់ចែងផ្សព្វផ្សាយនិងអនុវត្តខ្លឹមសារនេះ ឱ្យមានប្រសិទ្ធភាព**ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២២** តទៅ តាមការគួរ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា** ទទួលនូវគារវកិច្ចពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា "**ដើម្បីជូនជ្រាប**"
- សភាពាណិជ្ជកម្មកម្ពុជា "**ដើម្បីជូនជ្រាប និងសហការផ្សព្វផ្សាយ**"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# តារាងរាយមុខទំនិញដែលពន្ធនិង/ឬអាករត្រូវបានដាក់ជាបន្ទុករដ្ឋ

(អមភ្ជាប់លិខិតលេខ៥៥៣០ សហវ.អគរ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)

| ល.រ | មុខទំនិញ | លេខកូដទំនិញ<br>ស្របតាមតារាងពន្ធគយកម្ពុជាឆ្នាំ ២០២២ |
|---|---|---|
| I. | **ពន្ធគយជាបន្ទុករដ្ឋ ÷** | |
| ១. | ពូជដំណាំនិងពូជសត្វគ្រប់ប្រភេទ ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័ន មានសមត្ថកិច្ច | តារាងពន្ធគយជាធរមាន |
| II. | **អាករលើតម្លៃបន្ថែមជាបន្ទុករដ្ឋ ÷** | |
| ១. | ពូជដំណាំ និងពូជសត្វគ្រប់ប្រភេទដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័ន មានសមត្ថកិច្ច | តារាងពន្ធគយជាធរមាន |
| ២. | ចំណីសត្វ និងវត្ថុធាតុដើមផលិតចំណីសត្វ | ជំពូកទី ២៣ |
| ៣. | បសុឱសថដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័ន មានសមត្ថកិច្ច | តារាងពន្ធគយជាធរមាន |
| ៤. | ជីកសិកម្ម ដែលមានការបញ្ជាក់ទទួលស្គាល់ពីស្ថាប័ន មានសមត្ថកិច្ច | ជំពូកទី ៣១ |
| ៥. | ថ្នាំសម្លាប់សត្វល្អិត | ទីតាំង ៣៨.០៨ |
| ៦. | ម៉ាស៊ីនបូមទឹក | ៨៤១៣.១៩.១០ ៨៤១៣.១៩.២០ ៨៤១៣.២០.១០<br>៨៤១៣.៥០.៣១ ៨៤១៣.៥០.៣២ ៨៤១៣.៥០.៤០<br>៨៤១៣.៥០.៩០ ៨៤១៣.៦០.៣១ ៨៤១៣.៦០.៣២<br>៨៤១៣.៦០.៤០ ៨៤១៣.៦០.៩០ ៨៤១៣.៧០.១១<br>៨៤១៣.៧០.១៩ ៨៤១៣.៧០.៣១ ៨៤១៣.៧០.៣៩<br>៨៤១៣.៧០.៤២ ៨៤១៣.៧០.៤៣ ៨៤១៣.៧០.៤៩<br>៨៤១៣.៧០.៥១ ៨៤១៣.៧០.៥៩ ៨៤១៣.៧០.៩១<br>៨៤១៣.៧០.៩៩ ៨៤១៣.៨១.១៣ ៨៤១៣.៨១.១៤<br>៨៤១៣.៨១.១៥ ៨៤១៣.៨១.១៩ ៨៤១៣.៨២.១០<br>និង ៨៤១៣.៨២.២០ ។ |
| ៧. | ម៉ាស៊ីនសម្ងួតសម្រាប់កសិកម្ម | ៨៤១៩.៣៣.១០ ៨៤១៩.៣៤.១០ ៨៤១៩.៣៤.២០<br>និង ៨៤១៩.៣៤.៩០ ។ |
| ៨. | ឧបករណ៍បម្រើការងារកសិកម្ម សាកវប្បកម្ម និងរុក្ខសាស្ត្រ សម្រាប់ការរៀបចំដី ឬការដាំដុះ | ៨៤៣២.១០.០០ ៨៤៣២.២១.០០ ៨៤៣២.២៩.០០<br>៨៤៣២.៣១.០០ ៨៤៣២.៣៩.០០ ៨៤៣២.៤១.០០<br>៨៤៣២.៤២.០០ ៨៤៣២.៨០.១០ ៨៤៣២.៨០.៩០<br>៨៤៣២.៩០.១០ និង ៨៤៣២.៩០.៩០ ។ |
| ៩. | ម៉ាស៊ីនសម្រាប់ច្រូតកាត់ ឬបោកបែន រួមទាំងម៉ាស៊ីនចងចំបើង ម៉ាស៊ីនកាត់ស្មៅ ម៉ាស៊ីនសម្អាត ជ្រើសរើសស៊ុតផ្លែឈើ ឬផលិតផលកសិកម្មផ្សេងទៀត | ៨៤៣៣.២០.០០ ៨៤៣៣.៣០.០០ ៨៤៣៣.៤០.០០<br>៨៤៣៣.៥១.០០ ៨៤៣៣.៥២.០០ ៨៤៣៣.៥៣.០០<br>៨៤៣៣.៥៩.២០ ៨៤៣៣.៥៩.៩០ ៨៤៣៣.៦០.១០<br>និង ៨៤៣៣.៦០.២០ ។ |

| | | |
|---|---|---|
| ១០. | ម៉ាស៊ីន និងឧបករណ៍ផ្សេងទៀតប្រើក្នុងវិស័យកសិកម្ម សាកវប្បកម្ម រុក្ខកម្ម ចិញ្ចឹមសត្វបសុបក្សី ឬចិញ្ចឹមឃ្មុំ រួមទាំងម៉ាស៊ីនបណ្ដុះដោយប្រើមេកានិក ឬប្រើកំដៅ ម៉ាស៊ីនភ្ញាស់និងកំដៅពងបសុបក្សី | ៨៤៣៦.១០.១០ ៨៤៣៦.១០.២០ ៨៤៣៦.២១.១០<br>៨៤៣៦.២១.២០ ៨៤៣៦.២៩.១០ ៨៤៣៦.២៩.២០<br>៨៤៣៦.៨០.១១ ៨៤៣៦.៨០.២១ ៨៤៣៦.៩១.០០<br>៨៤៣៦.៩៩.១១ និង ៨៤៣៦.៩៩.២១ ។ |
| ១១. | ម៉ាស៊ីនសម្អាត ជ្រើសរើស គ្រាប់ពូជ ធញ្ញជាតិ ឬបន្លែស្ងួត ម៉ាស៊ីនប្រើក្នុងឧស្សាហកម្មធ្វើម្សៅ ឬប្រព្រឹត្តកម្មនៃគ្រាប់ធញ្ញជាតិ ឬបន្លែស្ងួត ក្រៅពីម៉ាស៊ីនប្រើក្នុងកសិដ្ឋាន | ៨៤៣៧.១០.១០ ៨៤៣៧.១០.២០ ៨៤៣៧.១០.៣០<br>៨៤៣៧.១០.៤០ ៨៤៣៧.៨០.១០ ៨៤៣៧.៨០.២០<br>៨៤៣៧.៨០.៥១ និង ៨៤៣៧.៨០.៦១ ។ |
| ១២. | គោយន្ត និងត្រាក់ទ័រកសិកម្ម | ៨៧០១.១០.១១, ៨៧០១.១០.១៩, ៨៧០១.១០.៩១,<br>៨៧០១.១០.៩៩, ៨៧០១.៩១.១០, ៨៧០១.៩២.១០,<br>៨៧០១.៩៣.១០, ៨៧០១.៩៤.១០, និងទីតាំងរង<br>៨៧០១.៩៥.១០ ។ |
| III. **អាករនាំចេញជាបន្ទុករដ្ឋ ÷** | | |
| ១. | កម្ទេច ឬចំណាំងឈើ អាចម៍រណា កម្ទេចឈើផលិត ឬកែច្នៃចេញពីឈើដាំក្នុងស្រុក ដូចជាដើមអាកាស្យា និងដើមប្រេងខ្យល់ ជាដើម | ៤៤០១.២១.០០ ៤៤០១.២២.០០ ៤៤០១.៣១.០០<br>និង ៤៤០៤.២០.១០ ។ |
| ២. | ផលិតផលជលផលបានពីសកម្មភាពវារីវប្បកម្ម | ជំពូកទី៣ |
| ៣. | ឈើ និងផលិតផលពីឈើដាំក្នុងស្រុក<br>***(ចំនុច ២ នៃលិខិតលេខ ៣៦៥៥ អតរ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩-ដាក់អាករនាំចេញជាបន្ទុករដ្ឋ)*** | តារាងពន្ធគយជាធរមាន |